## ស្ថានសម្រាលទោស (mitigating circumstances)

ស្ថានសម្រាលទោស ជាកត្តា ដែលនាំឲ្យមានការបន្ថយទោស។ បទបញ្ជាថ្នាក់លើ (superior order) អាចជាមូលដ្ឋានមួយ (មាត្រា ៧.៤ នៃ ICTY)។

កត្តាដែលប្រកាន់យកដោយតុលាការអន្តរជាតិ មានដូចជា៖ ស្ថានភាពបុគ្គល (គ្រួសារ, អាយុ, សុខភាព) ចរិតល្អ ការសហការជាដុំកំភួនជាមួយរដ្ឋអាជ្ញា (substantial cooperation) ការសារភាពកំហុស វិប្បដិសារី ការជួយជនរងគ្រោះ ការព្រមប្រគល់ខ្លួនដោយស្ម័គ្រចិត្ត តួនាទីរាយរងក្នុងបទល្មើស ការប្រព្រឹត្តល្អក្នុងអំឡុងពេលឃុំខ្លួន ការបង្ខិតបង្ខំ (duress) ភាពទន់ខ្សោយផ្លូវចិត្ត (diminished mentality)។

តាមវិធាននីតិវិធី ICC ត្រូវបានតម្រូវឲ្យថ្លឹងថ្លែងនូវកត្តាសម្រាល និងទម្ងន់ទោស ព្រមទាំងពិចារណា កាលៈទេសៈនៃពិរុទ្ធជន និងបទល្មើស។ កាលៈទេសៈទាំងនោះ ដូចជា ការបង្ខិតបង្ខំ ដែលជាមូលដ្ឋាន សម្រាប់បដិសេធនូវការទទួលខុសត្រូវព្រហ្មទណ្ឌ។

មិនមានបញ្ជីសរុបទាំងស្រុង នៃកត្តាបន្ថយទោសទេ (non-exhaustive) (Antonio Cassese, the Oxford Companion to International Criminal Justice, 2009, pp. 423-424)។